**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ...សហវ....

មកដល់ក្រសួង អ.យ.ក
ថ្ងៃទី 28 ខែ 10 ឆ្នាំ 2024
ម៉ោង ............ នាទី ចុះលេខ 5289

ថ្ងៃ...ខែ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២៤

## ជម្រាបជូន

## ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ៖** ករណីការស្នើសុំរបស់ក្រសួងអប់រំ យុវជន និងកីឡា ១). ការដំឡើងអត្រាចំនួនសិស្សទទួលបានអាហារូបករណ៍អប់រំបច្ចេកទេសពី ៣៥% ទៅ ៥០% ២). ការស្នើសុំផ្តល់អាហារូបករណ៍ និងបង់ថ្លៃសិក្សាជូននិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត លើមុខវិជ្ជា STEM និង ៣). ការស្នើសុំថវិកាឧបត្ថម្ភសាលារៀនគំរូ។

**យោង ៖** -ស្មារតីកិច្ចប្រជុំចរចាថវិកាឆ្នាំ ២០២៥ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២៤

-លិខិតលេខ ២៦១៧ អយក.ហវ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជ្រាបថា ពាក់ព័ន្ធនឹងករណីការស្នើសុំខាងលើ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចជាគោលការណ៍ ដូចខាងក្រោម៖

១. ឯកភាពការដំឡើងអត្រាចំនួនសិស្សទទួលបានអាហារូបករណ៍អប់រំបច្ចេកទេសពី ៣៥% ទៅ ៥០% និងការដំឡើងប្រាក់អាហារូបករណ៍ប្រចាំខែពី ៣០ ០០០ រៀល ទៅត្រឹម ៥០ ០០០ រៀល ដោយអនុវត្តចាប់ពីឆ្នាំសិក្សា ២០២៤-២០២៥ តទៅ។

២. ឯកភាពការផ្តល់អាហារូបករណ៍ និងការបង់ថ្លៃសិក្សាជូននិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត លើមុខវិជ្ជា STEM ដោយប្រើប្រាស់មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ (Budget Support) ស្របតាមកិច្ចព្រមព្រៀងហិរញ្ញប្បទានលេខ ACT-61732 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២៤ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហគមន៍អឺរ៉ុប ដោយក្នុងនោះ៖

- និស្សិតជំនាន់ទី ១ ចំនួន ១៨៥ នាក់ ចាប់ពីឆ្នាំសិក្សា ២០២៥-២០២៦ តទៅ
- និស្សិតជំនាន់ទី ២ ចំនួន ៣១៥ នាក់ ចាប់ពីឆ្នាំសិក្សា ២០២៦-២០២៧ តទៅ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

៣. មិនឯកភាពការផ្តល់ថវិកាឧបត្ថម្ភសាលារៀនគំរូ ដែលបានស្នើសុំតាមរយៈលិខិតលេខ ២៦១៧ អយក.ហវ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ឡើយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរតនាគារជាតិ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ